# ភីលីព ១:១-១១
# ដៃគូនៅក្នុងដំណឹងល្អ

សូមអានភីលីព ១:១-១១ ទាំងមូល។
សូមអាន ខ១-២ ម្តងទៀត។
តើលោកប៉ុលបានសរសេរសំបុត្រនេះទៅកាន់នរណា?

**ការពន្យល់** ពាក្យ ‹*អ្នកត្រួតត្រា*› ‹*ចាស់ទុំ*› និង ‹*គ្រូគង្វាល*› បានជំនួសគ្នានៅក្នុងសញ្ញាថ្មី គឺថាទាំងបីគឺជាឋានៈឬតួនាទីដូចគ្នា។ ដូច្នេះនៅក្នុងខ១ នៅពេលលោកប៉ុលសរសេរសំបុត្រនេះទៅកាន់ ‹*អ្នកត្រួតត្រា*› នោះមានន័យថាគាត់បានសរសេរទៅកាន់គ្រូគង្វាល (គឺចាស់ទុំ)។

សូមអាន ខ៣-៦
ហេតុអ្វីបានជាលោកប៉ុលទូលអង្វរដោយអំណរនៅពេលគាត់អធិស្ឋានឲ្យពួកភីលីព?

តើពួកភីលីពបានជួយលោកប៉ុលក្នុងដំណឹងល្អយ៉ាងដូចម្តេច? សូមមើល ភីលីព ១:១៩ ២:២៥ ៤:១៤-១៨។

**ការពន្យល់ និង អនុវត្តន៍** គ្រីស្ទបរិស័ទគឺជាដៃគូនៅក្នុងដំណឹងល្អ។ ជីវិតរបស់យើងត្រូវមានគោលបំណងបំរើដំណឹងល្អ ប៉ុន្តែយើងមិនបំរើដំណឹងល្អទីទៃពីគ្នានោះទេ។ យើងត្រូវរួមគ្នា និង ជួយគ្នាទៅវិញទៅមកក្នុងការបំរើដំណឹងល្អ ដូច*ជា*ពួកជំនុំនៅភីលីពបានជួយលោកប៉ុលដែរ។ តើអ្នកបានធ្វើអ្វីខ្លះដើម្បីនឹងសម្រេចតួនាទីជាដៃគូនៅក្នុងដំណឹងល្អ? តើសមាជិកនៅពួកជំនុំមានអាកប្បកិរិយា(ដែលបង្ហាញ)ថា គេជាដៃគូនៅក្នុងដំណឹងល្អឬទេ? សូមពិភាក្សា។

សូមអាន ខ៧-៨
**ការពន្យល់ និង អនុវត្តន៍** ស្ថានភាពរបស់លោកប៉ុលគឺគាត់ជាប់ចំណងពីព្រោះគាត់ប្រកាសដំណឹងល្អ ប៉ុន្តែគាត់មិនក្រៀមក្រំទេ ផ្ទុយទៅវិញ គាត់មានអំណរដោយព្រោះពួកភីលីពបានជួយគាត់នៅក្នុងដំណឹងល្អ។ តើអ្នកនឹងមានអាកប្បកិរិយាយ៉ាងម៉េចប្រសិនបើអ្នកជាប់គុកដោយព្រោះដំណឹងល្អ ម្តងវិញនោះ?

សូមអាន ខ៩-១១
តើលោកប៉ុលបានអធិស្ឋានយ៉ាងដូចម្ដេចសំរាប់ពួកភីលីព?

**ការពន្យល់ និង អនុវត្តន៍** សូមកត់សំគាល់ថា ទោះបីជាលោកប៉ុលជាប់គុកក៏ដោយ ក៏គាត់នៅតែបន្តអធិស្ឋានអំពីជីវិតខាងឯព្រលឹងវិញ្ញាណរបស់គ្រីស្ទបរិស័ទជានិច្ច។ គាត់មិនគ្រាន់តែគិតអំពីតម្រូវការរបស់ខ្លួនប៉ុណ្ណោះទេ។ តើយើងបានរៀនអ្វីខ្លះពីគំរូរបស់លោកប៉ុល?

ចូរយកខ៩-១១ជាគំរូសំរាប់អ្នក និង អធិស្ឋានសំរាប់សមាជិកនៅពួកជំនុំ។

**រំលឹកឡើងវិញ** តើអ្នកបានរៀនអ្វីខ្លះពី ភីលីព ១:១-១១?